**ប្រការ ៤** : រោងចក្រនេះត្រូវបានអនុញ្ញាអោយផលិតនូវមុខផលិតផល« បារី »ទៅតាមគំរូនិងផ្លាកសញ្ញាដែលតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

**ប្រការ ៥** : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសប្រការណាមួយដែលបានចែងខាងលើប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៦** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងលោក ចារ វេ រេ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀង ៗ ខ្លួន ។

**ប្រការ ៧** : ប្រកាសនេះមានអនុភាព គតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ពូ សុធីរៈ**

* * *

ភ្នំពេញ,ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ៣៥០ បឈ.ប្រក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦
- យោងកំណត់ហេតុកិច្ចប្រជុំអន្តរក្រសួង ស្តីពីកាងារអាស៊ាន ថ្ងៃទី ០៧-៥-១៩៩៦ នៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ពិនិត្យសំណូមពរតាំងចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** : បង្កើតការិយាល័យមួយឈ្មោះ ការិយាល័យកិច្ចការអាស៊ាន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ ។

**ប្រការ ២** : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ការិយាល័យនេះ អាស្រ័យដោយថ្នាក់ដឹកនាំនាយកដ្ឋានផែនការ កំណត់និងបានការឯកភាពពីថ្នាក់ដឹកនាំក្រសួង ។

**ប្រការ ៣** : លោកប្រធានមន្ទីរ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញកិច្ច លោកប្រធាននាយកដ្ឋានផែនការ និងអស់លោកប្រធាននាយកដ្ឋានពាក់ព័ន្ធមានបន្ទុករៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**តូ សុធីរ:**

* * *

## ២—ឯកសារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ប្រកាស

### ប្រកាសលេខ: ២៨៨ ប្រក.កសក

### ស្តីពីការអនុញ្ញាតអោយបង្កើតរោងចក្រកែច្នៃជលផល

### របស់ក្រុមហ៊ុន *CAMBODIA-THAI MARINE PRODUCTS CO. LTD*

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ កម្ពុជា